ធ៧-៩៥-០៤ ស.រ.ណ.ន

ភ្នំពេញ, ថ្ងៃទី២៣ ខែ០៦ ឆ្នាំ១៩៩៥

**ជម្រាបមក**

**លោកនាយកធនាគារពាណិជ្ជទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** : ការផ្ញើរបាយការណ៍សរុបទ្រព្យសកម្មនិងទ្រព្យអកម្មនៅលើថាសទន់។

**យោង** : អនុក្រិត្យលេខ ២៩ អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩២ស្តីពីការគ្រប់គ្រងធនាគារពាណិជ្ជ។

តបតាមកម្មវត្ថុ និងយោងខាងលើនេះ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការត្រួតពិនិត្យលើរបាយការណ៍ឱ្យកាន់តែសុក្រិត្យ និងប្រមូលផ្តុំតួលេខឱ្យបានទាន់ពេល នាយកដ្ឋានត្រួតពិនិត្យតម្រូវឱ្យបណ្តាធនាគារពាណិជ្ជទាំងអស់ត្រូវផ្ញើរបាយការណ៍ខាងលើដាក់ក្នុងថាសទន់ដែលមានសេចក្តីណែនាំ និងគំរូថាសទន់ស្រេចបន្ថែមលើរបាយការណ៍ប្រចាំខែចាប់តាំងពី ខែ០៦-៩៥ នេះតទៅ។

ការផ្ញើថាសទន់មកនាយកដ្ឋានត្រួតពិនិត្យដូចគ្នាចំពោះរបាយការណ៍សរុបទ្រព្យសកម្ម និងទ្រព្យអកម្ម (ក្រដាស) ដែលបានកំណត់ទុកក្នុងសារាចរណែនាំលេខ ធ៧-៩៥-០០២ សរណន ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៥។

តួលេខនៅលើថាសទន់គឺដូចគ្នាទាំងស្រុងនឹងតួលេខលើរបាយការណ៍សរុបទ្រព្យសកម្ម និងទ្រព្យអកម្ម (ក្រដាស)។

ថាសទន់និងសេចក្តីណែនាំលើការអនុវត្តសម្រាប់ថាសទន់ (Software) សូមទំនាក់ទំនងផ្ទាល់ជាមួយនាយកដ្ឋានត្រួតពិនិត្យ។

**នាយកដ្ឋានត្រួតពិនិត្យ**
**ជា សុខ**

**ទេសាភិបាលរង**
**ហត្ថលេខា និងត្រា: ជូឡុង សូម៉ូរ៉ា**